**រាជរដ្ឋាភិបាលកម្ពុជា**
**អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន**
**អគ្គលេខាធិការដ្ឋាន**
លេខ: ០១៨/១៨ អ.ជ.ប.គ.ញ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ថ្ងៃពុធ ៧កើត ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
រាជធានីភ្នំពេញ, ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៨

# របាយការណ៍
## ស្តីពី
## លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ខែមករា និងទិសដៅការងារ ខែកុម្ភៈ ឆ្នាំ២០១៨

(២៦/១២/២០១៧ - ២៥/០១/២០១៨)

យោងតាមផែនការជាតិ៣ឆ្នាំស្តីពីការត្រួតពិនិត្យគ្រឿងញៀន (២០១៦-២០១៨) និងការអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ឆ្នាំ២០១៨ របស់រាជរដ្ឋាភិបាល អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តអនុវត្តការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្នុងគោលដៅចូលរួមចំណែកអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាពរបស់រាជរដ្ឋាភិបាល សំដៅរក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ និងលើកកម្ពស់សុខុមាលភាពជូនប្រជាពលរដ្ឋ ។ តាមរយៈ ការអនុវត្តផែនការសកម្មភាពនៃទិសដៅការងារខាងលើ នៅក្នុងខែមករានេះ យើងបានធ្វើការកត់សម្គាល់អំពីសភាពការណ៍ និងអនុវត្តការងារទទួលបានលទ្ធផលដូចខាងក្រោម ៖

## I. សភាពការណ៍គ្រឿងញៀន

ក្នុងចំណោមបទល្មើសគ្រឿងញៀនដែលបង្ក្រាបបានក្នុងខែមករានេះ យើងបានកត់សម្គាល់ឃើញក្រុមឧក្រិដ្ឋជននៅតែបន្តធ្វើសកម្មភាពចរាចរដឹកជញ្ជូនគ្រឿងញៀនខុសច្បាប់ ពីតំបន់ត្រីកោណមាស ឆ្លងកាត់ប្រទេសឡាវចូលមកកម្ពុជាតាមបណ្តាច្រករបៀងនៃខេត្តនៅភាគឥសានប្រទេសចំនួន ៤ ករណីធំៗ ដែលត្រូវបានកងកម្លាំងនៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ខេត្តក្រចេះ ត្បូងឃ្មុំ និងខេត្តព្រះសីហនុ បង្ក្រាបទាន់ពេលវេលា។

ដោយឡែក ការចរាចរដឹកជញ្ជូនគ្រឿងញៀនតាមផ្លូវអាកាសបានកើតឡើងចំនួន ២ ករណី ៖

- ករណីទី១ ធ្វើពីប្រទេសប្រេស៊ីល ចូលមកកម្ពុជាតាមច្រកអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ប៉ុន្តែត្រូវបានសមត្ថកិច្ចចម្រុះនៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ បង្ក្រាបទាន់ពេលវេលា
- ករណីទី២ ធ្វើពីប្រទេសកម្ពុជា ទៅប្រទេសអូស្ត្រាលី តាមច្រកព្រលានយន្តហោះអន្តរជាតិភ្នំពេញ ប៉ុន្តែត្រូវកម្លាំងជំនាញក្រុមស៊ើបអង្កេតបទល្មើសឆ្លងកាត់ព្រំដែន (TCT) បង្ក្រាបបាន ។

ជារួម សភាពការណ៍គ្រឿងញៀននៅទូទាំងប្រទេសមានការថយចុះ ជាពិសេស នៅភូមិសាស្ត្ររាជធានីភ្នំពេញ ក្រោយការអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី២ របស់រាជរដ្ឋាភិបាល យើងសង្កេតឃើញស្ទើរតែគ្រប់ខណ្ឌក្នុងរាជធានីភ្នំពេញ សកម្មភាពជួញដូរ ប្រើប្រាស់គ្រឿងញៀន មានការថយចុះ ដោយសារសមត្ថកិច្ចបានធ្វើការបង្ក្រាបបន្តបន្ទាប់ ។



អគ្គលេខាធិការដ្ឋាន នៃ អ.ជ.ប.គ.ញ មានទីតាំងនៅក្នុងបរិវេណក្រសួងមហាផ្ទៃ, Phone, Fax: (855) 23 721 648, Fax: (855) 23 727 529 P.O.Box: 151
E-mail: info@nacd.gov.kh Website : www.nacd.gov.kh

## II. អំពីការចាត់ដឹកនាំ ៖

**ការចាត់ដឹកនាំរបស់ស្ថាប័នកំពូលថ្នាក់ជាតិ**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ក្នុងនាមប្រមុខនៃរាជរដ្ឋាភិបាល បានណែនាំឱ្យបន្តការអនុវត្ត ផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ រយៈពេលមួយឆ្នាំ២០១៨បន្ថែមទៀត ដោយរក្សាយន្តការ និងផែនការសកម្មភាពទាំងអស់នៃយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ ឆ្នាំ២០១៧ ក្រោមការដឹកនាំរបស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** រួមទាំងយន្តការពហុវិស័យ និងផែនការជាតិ៣ឆ្នាំ ក៏ដូចជាទិសដៅការងារសម្រាប់អនុវត្តក្នុងឆ្នាំ២០១៨ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

**ការចាត់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន**

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** ប្រធាន អ.ជ.ប.គ.ញ បានបន្តដឹកនាំ និងណែនាំលើការងារសំខាន់ៗ ជាពិសេសការងារពាក់ព័ន្ធ ការអនុវត្តផែនការជាតិស្តីពីការត្រួតពិនិត្យគ្រឿងញៀន នឹងអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ ឆ្នាំ២០១៨ ដូចខាងក្រោម ៖

**១. ការងារអប់រំ ផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន ៖** បានជំរុញឱ្យបន្តការអនុវត្តផែនការតាមរយៈវិធានការផ្សព្វផ្សាយអប់រំដូចជា ការរៀបចំ វេទិកាតុមូល ការអប់រំសិស្ស និស្សិត ការអប់រំកម្មករការផ្សព្វផ្សាយតាមបណ្តាញព័ត៌មាន ការផ្សព្វផ្សាយតាម ប្រព័ន្ធទូរស័ព្ទ ការបិទតាំងខ្លឹមសារអប់រំតាមគោលដៅទេសចរណ៍ ការរៀបចំវេទិកាជួបវិស័យឯកជន ។

**២. ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងការចាកចេញពីគ្រឿងញៀន ៖** បានណែនាំឱ្យបន្តពង្រឹងសមត្ថភាពមណ្ឌលបណ្តោះអាសន្នរដ្ឋនិងឯកជនឱ្យមាននិរន្តរភាព ដើម្បី ទទួលជនរងគ្រោះដែលអង្គភាពអនុវត្តន៍ច្បាប់ ស្ថាប័នតុលាការបញ្ជូនទៅទទួលសេវាព្យាបាល, ត្រូវពង្រឹងពង្រីក សេវាព្យាបាលដោយផ្អែកលើសហគមន៍តាមមណ្ឌលសុខភាពនិងមន្ទីរពេទ្យបង្អែកបន្ថែមទៀត ។ ជាមួយនេះ ត្រូវពិនិត្យស្នើសុំមូលនិធិសមធម៌ដល់អ្នកញៀនគ្រឿងញៀន ឱ្យបានទទួលសេវាពិនិត្យ និងព្យាបាលភាពញៀនគ្រឿងញៀន ដោយឥតគិតថ្លៃនៅតាមមូលដ្ឋានសុខាភិបាលសាធារណៈ ព្រមទាំងពង្រឹងសេវាគាំទ្រផ្សេងៗទៀត សំដៅលើកកម្ពស់ប្រសិទ្ធភាពនៃការធ្វើសមាហរណកម្មទៅក្នុងគ្រួសារ និងសហគមន៍ ដើម្បីកាត់បន្ថយការលាប់គ្រឿងញៀនឡើងវិញ ។

**៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តន៍ច្បាប់ ៖** ត្រូវបន្តពង្រឹងសមត្ថភាពមន្ត្រីអនុវត្តន៍ច្បាប់តាមរយៈការបណ្តុះបណ្តាលជំនាញត្រួតពិនិត្យគ្រឿងញៀន និងសារធាតុគីមីផ្សំ តាមមេរៀន ក្នុងប្រព័ន្ធកុំព្យូទ័រ **(CBT)**, តាមប្រព័ន្ធអេឡិចត្រូនិក (e-Learning), និងការបណ្តុះបណ្តាលជំនាញផ្សេងៗទៀតដល់មន្ត្រីអនុវត្តន៍ច្បាប់គ្រប់ប្រភេទនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងក្រុមជនបង្គោលនៃកងយោធពលខេមរភូមិន្ទ និងបន្តពង្រឹងសមត្ថភាពមន្ត្រីបម្រើការងាររបស់ការិយាល័យទំនាក់ទំនងព្រំដែន **(BLO)** ។ ទន្ទឹមនេះ ត្រូវពន្លឿននីតិវិធីក្នុងការជម្រះក្តីពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន ជាពិសេស រឿងក្តីដែលពាក់ព័ន្ធនឹងការរឹបអូសទ្រព្យសម្បត្តិឱ្យបានឆាប់ដើម្បីគណៈកម្មការ ការតាមដាន ការប្រមូល ការគ្រប់គ្រង និងការចាត់ចែងទ្រព្យសម្បត្តិ បន្តនីតិវិធីហិរញ្ញវត្ថុ ឱ្យទាន់ពេលវេលា ចៀសវាងការខូចខាត ធ្លាក់ចុះតម្លៃ ឬឈានដល់បាត់បង់តម្លៃទាំងស្រុងនៃទ្រព្យ សម្បត្តិទាំងនោះ ។

**៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ ៖** បានណែនាំឱ្យរៀបចំកិច្ចប្រជុំក្រុមការងារអន្តរក្រសួងត្រួតពិនិត្យសារធាតុគីមីផ្សំ និងក្រុមលេខានៃក្រុមការងារនេះ ។ ជាមួយនេះ ត្រូវសហការជាមួយក្រសួងឧស្សាហកម្ម និងសិប្បកម្ម

បន្តការរៀបចំសេចក្តីព្រាងបទប្បញ្ញត្តិស្តីពីការបិទស្លាកសញ្ញា ការទុកដាក់ ការវេចខ្ចប់នូវសារធាតុគីមីក្នុង វិស័យឧស្សាហកម្ម ។

**៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន ៖** បន្តអនុវត្តនូវរាល់កិច្ចការ ដែលបានព្រមព្រៀងគ្នាកន្លងមកជាមួយភាគីថៃ ឡាវ និង វៀតណាម ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនឆ្លងកាត់ព្រំដែនព្រមទាំងការអនុវត្តគម្រោងសុវត្ថិភាពទន្លេមេគង្គក្រោមសម្រាប់ប្រទេសកម្ពុជា ថៃ និងឡាវ ជាពិសេសការរៀបចំភូមិ ស គ្មានគ្រឿងញៀនចំនួន៥ នៅតាមព្រំដែនដែលភាគីកម្ពុជា ឡាវ ថៃ បានឯកភាពគ្នាកន្លងមកដោយមានកិច្ចអន្តរាគមន៍នានាដែលមានលក្ខណៈពហុវិស័យ ដើម្បីធ្វើជាគំរូដកបទពិសោធន៍ និងការពង្រឹង ពង្រីកការិយាល័យ(**BLO**) ៥កន្លែង តាមបណ្តោយព្រំដែន កម្ពុជា-ឡាវ, កម្ពុជា-ថៃ ។

**៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់និងដៃគូអភិវឌ្ឍន៍នានា ៖** បន្តអនុវត្តខ្លឹមសារនៃកិច្ចព្រមព្រៀងនានាទាំងក្នុងក្របខ័ណ្ឌទ្វេភាគី ពហុភាគី អង្គការ **UNODC** បណ្តាប្រទេសក្នុងអនុតំបន់តំបន់ អន្តរជាតិ ការអនុវត្តគម្រោងសុវត្ថិភាពទន្លេមេគង្គ (Safe Mekong Project) ។

**៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ៖** ត្រូវបន្តការកែសម្រួលមាត្រាមួយចំនួននៅក្នុងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនពាក់ព័ន្ធនឹងការរឹបអូសទ្រព្យសម្បត្តិ ដែលជាផលបានមកពីបទល្មើសគ្រឿងញៀន និងបន្តស្នើសុំពិនិត្យ និងសម្រេចលើសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការរៀបចំ និងការ ប្រព្រឹត្តទៅនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។ ជាមួយនេះ ត្រូវធ្វើការណែនាំឱ្យរាជធានី-ខេត្ត បង្កើតគណៈកម្មការសម្របសម្រួលសម្រាប់ការព្យាបាល និងស្តារនីតិសម្បទា នៅឃុំ-សង្កាត់ ដើម្បីគាំទ្រដល់មណ្ឌលសុខភាព សម្រាប់ការព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ ។

ក្រៅពីការងារដឹកនាំខាងលើ ៖

- ឯកឧត្តម កៅ ខុនដារ៉ា អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងជាប្រធានគណៈកម្មការទទួលបន្ទុកកិច្ចសហប្រតិបត្តិការអន្តរជាតិ នៃយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿញៀនខុសច្បាប់ បាន ៖

  - បានដឹកនាំប្រតិភូចុះត្រួតពិនិត្យការអនុវត្តផែនការភូមិសគ្មានគ្រឿងញៀន និងចែកសម្ភារសម្រាប់អនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿញៀនខុសច្បាប់ កាលពីថ្ងៃទី០៩-១២ ខែមករា ឆ្នាំ២០១៨ នៅខេត្តព្រះវិហារ និងខេត្តស្ទឹងត្រែង អ្នកចូលរួម ៣០០នាក់
  - ចូលរួមកិច្ចប្រជុំទ្វេភាគី និងទស្សនកិច្ចនៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ដែលដឹកនាំដោយ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី** រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាមួយក្រសួងសន្តិសុខឡាវ កាលពីថ្ងៃទី១៤-១៩ ខែមករា ឆ្នាំ២០១៨ ។

## III. លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

ឆ្លើយតបទៅនឹងទិសដៅការងារដែលបានដាក់ចេញកាលពីខែធ្នូ ឆ្នាំ២០១៧ និងតាមការណែនាំរបស់ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត បានបន្តអនុវត្តការងារទទួលលទ្ធផលដូចខាងក្រោម ៖

### ១. ការអប់រំ ផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន

**១.១** ការងារអប់រំតាមប្រព័ន្ធផ្សព្វផ្សាយ

- អគ្គលេខាធិការ បានចូលរួមផ្តល់កិច្ចសម្ភាសន៍ ក្រោមប្រធានបទស្តីពី លទ្ធផលនៃការអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀន លើកទី២ របស់រាជរដ្ឋាភិបាល កាលពីថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៧

នៅស្ថានីយ ទូរទស្សន៍ហង្សមាស ។

- សហការជាមួយស្ថានីយទូរទស្សន៍ NiceTV អញ្ជើញតំណាងគណៈអភិបាលខេត្តបន្ទាយមានជ័យ សៀមរាប ព្រះវិហារ និងខេត្តកំពង់ធំ ធ្វើជាវាគ្មិនក្នុងកម្មវិធី Share (បទពិសោធន៍ខ្ញុំ) ក្រោមប្រធានបទ យុវជននិងគ្រឿងញៀន ។

- សហការជាមួយស្ថានីយទូរទស្សន៍ ស៊ី.អិន.ស៊ី អញ្ជើញតំណាងអគ្គស្នងការដ្ឋាននគរបាលជាតិ ចូលរួមផ្តល់កិច្ចសម្ភាសន៍ក្នុងកម្មវិធីព័ត៌មានពេលថ្ងៃត្រង់ និងបញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ ចូលរួមផ្តល់កិច្ចសម្ភាសន៍ក្នុងកម្មវិធីព័ត៌មានពេលល្ងាច ក្រោមប្រធានបទការអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី២ ។

### **១.២ ការងារអប់រំតាមសហគមន៍**

ក្នុងខែមករានេះ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត បានធ្វើការអប់រំផ្សព្វផ្សាយពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀនដែលមានមហាជនទៅទទួលសារអប់រំចំនួន **១៣៦.២១១ នាក់** ។

ក្នុងនោះ ការងារអប់រំដែលអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បានសហការអនុវត្តមានដូចខាងក្រោម ៖

- ក្រសួងទេសចរណ៍ ចូលរួមវេទិកាជួបជាមួយវិស័យឯកជន ដើម្បីអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី២ (ថ្ងៃទី២៧-២៩ ខែធ្នូ ឆ្នាំ២០១៧) នៅខេត្តកំពង់ធំ និងខេត្តពោធិ៍សាត់ អ្នកចូលរួមចំនួន ៣៥៦ នាក់

- ក្រសួងអប់រំ យុវជន និងកីឡា ធ្វើការប្រឡងប្រណាំងថ្នាក់ជាតិ គូរគំនូរ និងតែងកំណាព្យ ក្រោមប្រធានបទ "ការអប់រំដើម្បីអភិវឌ្ឍន៍សង្គមគ្មានគ្រឿងញៀន" នៅតាមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន កាលពីថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៨ នៅក្រសួងអប់រំ យុវជន និងកីឡា

- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្របសម្រួលផ្សព្វផ្សាយពីផលប៉ះពាល់បញ្ហាគ្រឿងញៀនជូនដល់និស្សិតថ្នាក់ឆ្នាំមូលដ្ឋាននៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម កាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៨ អ្នកចូលរួម ៧៥០ នាក់

- បន្តសហការជាមួយក្រុមហ៊ុន HD&S Group Co.,LTD បានបញ្ជ្រាបខ្លឹមសារពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន ក្នុងកម្មវិធីប្រគំតន្ត្រីទេសចរណ៍ ដែលមានអ្នកចូលរួម ៨០.១៥០នាក់

- បន្តសហការជាមួយក្រសួងសាធារណការ និងដឹកជញ្ជូន ស្នើក្រុមហ៊ុនដឹកជញ្ជូនទាំងអស់ឱ្យណែនាំអ្នកបើកបរ សូមកុំឱ្យប្រើប្រាស់គ្រឿងញៀនខុសច្បាប់ និងស្នើឱ្យមានការបិទខិតប័ណ្ណផ្សព្វផ្សាយយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ តាមរថយន្ត

- បន្តសម្របសម្រួលជាមួយក្រសួងអប់រំយុវជន និងកីឡា អនុញ្ញាតឱ្យសមាគមយុវជនខ្មែរ (KYA) បើកវគ្គបណ្តុះបណ្តាល និងការសម្តែងរឿងខ្លី កម្មវិធីប្រកួតកីឡា កិច្ចពិភាក្សា ការរៀបចំសកម្មភាពអប់រំ និងសិក្ខាសាលាស្តីពី " លើកកម្ពស់ការចូលរួមរបស់យុវជនក្នុងការអប់រំបង្ការគ្រឿងញៀន និងគ្រឿងស្រវឹង " នៅតាមអនុវិទ្យាល័យ-វិទ្យាល័យ

- ការផ្សព្វផ្សាយឃ្លីបវីដេអូខ្លីស្តីពីបញ្ហាគ្រឿងញៀន និងការគោរពច្បាប់ចរាចរណ៍ផ្លូវគោក តាមបណ្តាញទំនាក់ទំនងសង្គម Facebook

- តាមរយៈគេហទំព័ររបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន (www.nacd.gov.kh) ក្នុងខែមករា ឆ្នាំ២០១៨ មានការចូលអានចំនួន **៤៥,៩៥១ ដង** ។

## ២. ការកាត់បន្ថយគ្រោះថ្នាក់ ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងចាកចេញពីគ្រឿងញៀន

### ២.១. ការកាត់បន្ថយគ្រោះថ្នាក់

២.១.១. បានចាត់មន្ត្រី ២ រូប ចូលរួមប្រមូលទិន្នន័យអង្កេតស្រាវជ្រាវចំណេះដឹង ស្តីពីជំងឺអេដស៍ ការប្រព្រឹត្តផ្លូវភេទ និងរកអត្រាប្រេវ៉ាឡង់មេរោគអេដស៍ក្នុងចំណោមអ្នកប្រើប្រាស់គ្រឿងញៀនឆ្នាំ២០១៧ នាថ្ងៃទី២៦-៣០ ខែធ្នូ ឆ្នាំ២០១៧ នៅខេត្តបន្ទាយមានជ័យ នាថ្ងៃទី០៩-១៦ ខែមករា ឆ្នាំ២០១៨ នៅខេត្តកំពង់ស្ពឺ និងខេត្តសៀមរាប។

២.១.២. ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ១រូប និងសមាជិកពេញសិទ្ធិ ១រូប ចូលរួមកិច្ចប្រជុំលើកទី២ របស់គណៈកម្មការសម្របសម្រួលត្រីភាគីប្រយុទ្ធនិងជំងឺអេដស៍ និងគ្រឿងញៀននៅកន្លែងធ្វើការ (TCC) ។

២.១.៣. បានចូលរួមកិច្ចប្រជុំពិភាក្សាអំពីការលើកសរសើរដល់សហគ្រាសគ្រឹះស្ថាន ដែលបានអនុវត្តការងារប្រយុទ្ធនិងជំងឺអេដស៍ និងគ្រឿងញៀននៅកន្លែងធ្វើការសម្រាប់ឆ្នាំ២០១៧ (ថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៨) នៅទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

២.១.៤. បន្តការគាំទ្រចំពោះការអនុញ្ញាតកម្មវិធីផ្តល់សេវាម្ជុល-សឺរ៉ាំង តាមរយៈអង្គការជាដៃគូ ចំពោះអ្នកប្រើប្រាស់គ្រឿងញៀនដោយចាក់ ដើម្បីកាត់បន្ថយការឆ្លងមេរោគអេដស៍ និងរោគឆ្លងតាមឈាមផ្សេងៗទៀត ។

២.១.៥. បន្តផ្តល់សេវាព្យាបាលជំនួស ដោយឱសថមេតាដូន ដល់អ្នកញៀនហេរ៉ូអ៊ីន (ពពួកអាភៀន) ។

### ២.២. ការព្យាបាល និងស្តារនីតិសម្បទា

២.២.១. បានជំរុញឱ្យគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី-ខេត្ត ពង្រឹងឬបង្កើតគណៈកម្មការសម្របសម្រួលការព្យាបាលអ្នកញៀនគ្រឿងញៀន នៅតាមឃុំ-សង្កាត់ ដើម្បីជំរុញអ្នកប្រើប្រាស់ និងញៀនគ្រឿងញៀនឱ្យទៅទទួលយកការព្យាបាល នៅតាមមណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក និងលើកកម្ពស់ការថែទាំបន្ត នៅតាមសហគមន៍ ។

២.២.២. ថ្នាក់ដឹកនាំអគ្គលេខាធិការរង ១រូប ចូលរួមកិច្ចប្រជុំស្តីពីគោលការណ៍ណែនាំប្រតិបត្តិការព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ កាលពីថ្ងៃទី១២ ខែមករា ឆ្នាំ២០១៨ រាជធានីភ្នំពេញ ។

២.២.៣. បន្តដំណើរការសាងសង់មជ្ឈមណ្ឌលផ្តល់សេវាព្យាបាលដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ដល់អ្នកញៀនគ្រឿងញៀននៅ ភូមិឫទ្ធី២ ឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ។

## ៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តន៍ច្បាប់

### ៣.១. ការពង្រឹងសមត្ថភាពការងារអនុវត្តន៍ច្បាប់

- ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ចូលជាសមាជិកក្រុមការងារបច្ចេកទេសអន្តរក្រសួង ប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម
- បានចាត់មន្ត្រី ២ រូប ទៅបើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីអនុវត្តន៍ច្បាប់គ្រឿងញៀន តាមប្រព័ន្ធអេឡិចត្រូនិច e-Learning នាថ្ងៃទី០៩-១២ ខែមករា ឆ្នាំ២០១៨ នៅខេត្តព្រះវិហារ និងខេត្តស្ទឹងត្រែង ។

### ៣.២. លទ្ធផលបង្ក្រាបបទល្មើសគ្រឿងញៀន

- បទល្មើសគ្រឿងញៀនសរុប **៦០៨ ករណី** (រួមទាំងបទល្មើសប្រើប្រាស់) លើ **៩១៤ ករណី** នៃខែធ្នូ ឆ្នាំ ២០១៧

- **ជនសង្ស័យឃាត់ខ្លួន ១.២៦៩នាក់ ស្រី ១១៩នាក់** (រួមទាំងជនប្រើប្រាស់) លើ **១.៨៦៤នាក់** នៃខែធ្នូ ឆ្នាំ២០១៧ ។ ជនសង្ស័យទាំងអស់មាន ០៥ សញ្ជាតិគឺ : ខ្មែរ ១.២៥៥នាក់ (ស្រី ១១៥នាក់), វៀតណាម ១០ នាក់ (ស្រី ០៤នាក់), កូរ៉េ ០១នាក់, ចិន ០២នាក់, បែលហ្សិក ០១នាក់ ។ ជនសង្ស័យទាំងនោះត្រូវបានកសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងរាជធានី-ខេត្ត

ក្នុងចំនួនបទល្មើសគ្រឿងញៀនខាងលើ ៖

➢ បទល្មើសគ្រឿងញៀន បង្ក្រាបដោយ **សមត្ថកិច្ចនគរបាល ៤៧៤ ករណី** ឃាត់ខ្លួនជនសង្ស័យ **៩៥៧ នាក់** (ស្រី ៨៤នាក់)

➢ បទល្មើសគ្រឿងញៀន បង្ក្រាបដោយ **សមត្ថកិច្ចកងរាជអាវុធហត្ថ ១៣៤ ករណី** ឃាត់ខ្លួនជនសង្ស័យ **៣១២ នាក់** (ស្រី ៣៥នាក់)

- **វត្ថុតាងគ្រឿងញៀនចាប់យក :** មេតំហ្វេតាមីនក្រាមម្សៅ(ICE) ២ គ.ក្រ ៨៥៦ ក្រាម ៩៧០ មិល្លីក្រាម, មេតំហ្វេតាមីនគ្រាប់(WY) ១៥១ ក្រាម ៦២០ មិល្លីក្រាម, អ៊ិចស្តាស៊ី ៣ គ.ក្រ ៨៣៥ ក្រាម ៨២០ មិល្លីក្រាម, កូកាអ៊ីន ១ គ.ក្រ ០០៣ ក្រាម ២៤០ មិល្លីក្រាម, កេតាមីន ៤ ក្រាម, កញ្ឆា ១ គ.ក្រ ៤៩៨ក្រាម ៧៥៦មិល្លីក្រាម, ដើមកញ្ឆា ៧.០៩៧ ដើម ។

**(សរុបរួម ៧ គ.ក្រ ៨៨០ ក្រាម ៧៧៧ មិល្លីក្រាម)**

- **ទ្រព្យសម្បត្តិសំខាន់ៗ** ចាប់យកក្នុងប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀន រួមមាន រថយន្ត ៧ គ្រឿង, ម៉ូតូ ១៩០ គ្រឿង, ទូរស័ព្ទ ៥៧៨ គ្រឿង, ជញ្ជីង ២៥ គ្រឿង, ប្រាក់កម្ពុជា ៧.៦៧៧.៥០០ រៀល, ប្រាក់ថៃ ១១.១៥០ បាត, ប្រាក់អាមេរិក ១.១៦៨ ដុល្លារ, ប្រាក់ឡាវ ៦៣០.០០០ គីប ។

- **ជនសង្ស័យចាប់តាមដីកា** មាន ៣១ ដីកា ចាប់បានជនសង្ស័យ ៣២នាក់ (ស្រី០២នាក់) ។

### ៣.៣. លទ្ធផលកោសលវិច័យលើសំណាកសង្ស័យជាគ្រឿងញៀន

- សំណាកសង្ស័យជាគ្រឿងញៀន ដែលបានធ្វើកោសលវិច័យ ក្នុងខែមករា ឆ្នាំ២០១៨ មាន **៤៩៤ ករណី** ស្មើនឹង **៥២៨សំណាក** ក្នុងនោះ ៖

- **សំណាកវិជ្ជមានសារធាតុញៀន** មាន **៤៨១ ករណី = ៥០៧ សំណាក** (៩៥,៩៨%) គឺ :
  - ➢ មេតំហ្វេតាមីនគ្រាប់ (WY) ២៦សំណាក = ៤,៩២%
  - ➢ មេតំហ្វេតាមីនក្រាមម្សៅ (ICE) ៤៦១សំណាក = ៨៧,៣១%
  - ➢ កូកាអ៊ីន ០៨សំណាក =១,៥១%
  - ➢ ហេរ៉ូអ៊ីន ០១សំណាក =០,១៨%
  - ➢ MDMA ០៧សំណាក = ១,៣២%
  - ➢ កេតាមីន ០៣សំណាក = ០,៥៦%
  - ➢ កញ្ឆា ០១សំណាក =០,១៨%

- **សំណាកអវិជ្ជមានសារធាតុញៀន ១៣ករណី = ២១សំណាក** (៣,៩៧%) ។

- បានផ្តល់តេស្តរកសារជាតុញៀនក្នុងទឹកនោមចំនួន ១១.០៧០ តេស្ត, ស្កត់តេស្ត ៥០ តេស្ត, កេតាមីនតេស្ត ៧៥ តេស្ត, កូកាអ៊ីនតេស្ត ២៥ តេស្ត, ម៉ាគ្វីតេស្ត ៥១០ តេស្ត, ម៉ាគ្វី ១ដប ស្មើនឹង ១០០ មិល្លីលីត្រ និងស្រោមវេចខ្ចប់ សំណាកសង្ស័យជាគ្រឿងញៀន ៤០០ សន្លឹក ដល់អង្គភាពចំនួន ១៧ រួមមានអគ្គស្នងការដ្ឋាននគរបាលជាតិ, មន្ទីរប្រឆាំងគ្រឿងញៀន, ស្នងការដ្ឋាននគរបាលខេត្តព្រះវិហារ, កងរាជអាវុធហត្ថខេត្តព្រះវិហារ, ស្នងការដ្ឋាននគរបាលខេត្តស្ទឹងត្រែង, កងរាជអាវុធហត្ថខេត្តស្ទឹងត្រែង, កងរាជអាវុធហត្ថខេត្តបន្ទាយមានជ័យ, ស្នងការដ្ឋាននគរបាលខេត្តសៀមរាប, សាលាខេត្តសៀមរាប, ស្នងការដ្ឋាននគរបាលខេត្តកំពង់ចាម, ស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ, ស្នងការដ្ឋាននគរបាលខេត្តត្បូងឃ្មុំ, ស្នងការដ្ឋាននគរបាលខេត្តកំពង់ធំ, សាលាដំបូងខេត្តកំពង់ធំ គណៈកម្មាការត្រួតពិនិត្យគ្រឿងញៀនខេត្តកោះកុង, គណៈកម្មាការត្រួតពិនិត្យគ្រឿងញៀនខេត្តបាត់ដំបង, គណៈកម្មាការត្រួតពិនិត្យគ្រឿងញៀនខេត្តឧត្តរមានជ័យ ។

## ៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ

សារជាតុញៀនក្នុងតារាងទី២ ទី៣ និងសារជាតុគីមីផ្សំក្នុងតារាងទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលបានអនុញ្ញាត ឱ្យនាំចូលក្នុង ខែមករា ឆ្នាំ២០១៨នេះ សរុបមាន **២.០០០** គ.ក្រ និង **១៥២** លីត្រ ក្នុងនោះ ៖

- ផ្តល់អាជ្ញាបណ្ណ័ និងលិខិតបញ្ជាក់មុខសញ្ញាស្តង់ដាប្រើប្រាស់សារជាតុគីមី ដោយក្រសួងឧស្សាហកម្ម និងសិប្បកម្ម មាន ១៥២ លីត្រ ។
- ចេញអាជ្ញាប័ណ្ណ ដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាមាន ២.០០០ គ.ក្រ ។
- បរិមាណនាំចូល ដោយក្រសួងសុខាភិបាលមាន ៣០១គ.ក្រ ៥៦៩ក្រាម ៨៧០មិល្លីក្រាម ៥០០ មីក្រូក្រាម

## ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន

៥.១. ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាននិងមន្ត្រី អ.ជ.ប.គ.ញ. ចូលរួមកិច្ចប្រជុំស្តីពីប្រតិបត្តិការតំបន់ត្រីកោណមាស ក្រោមផែនការកិច្ចសហប្រតិបត្តិការ៣ឆ្នាំ សម្រប់គម្រោងសម្របសម្រួលសុវត្ថិភាពទន្លេមេគង្គ (២០១៦-២០១៨) កាលពីថ្ងៃទី១៧-២០ ខែមករា ឆ្នាំ២០១៨ នៅខេត្តឈៀងរ៉ៃ ប្រទេសថៃ ។

៥.២. បានចាត់បញ្ជូនមន្ត្រីអគ្គលេខាធិការដ្ឋាន ១ រូប ទៅប្រចាំការនៅមជ្ឈមណ្ឌលសម្របសម្រួលសុវត្ថិភាពទន្លេមេគង្គ (SMCC) ដែលមានស្នាក់ការនៅក្នុងខេត្តឈៀងម៉ៃ ប្រទេសថៃ ។

៥.៣. បន្តសហការជាមួយភាគីវៀតណាម និងថៃ ក្នុងការសាងសង់មជ្ឈមណ្ឌលជាតិផ្តល់សេវាព្យាបាលដល់អ្នកញៀនគ្រឿងញៀនដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ នៅខេត្តព្រះសីហនុ ។

## ៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា

៦.១. បន្តកិច្ចសហការសម្របសម្រួល អនុវត្តក្នុងភាពជាដៃគូលើកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន ក្នុងក្របខ័ណ្ឌអនុតំបន់ តំបន់ អន្តរជាតិ ដូចជា សន្និសីទ វេទិកាសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ កិច្ចប្រជុំប្រចាំឆ្នាំ ការបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់ សិក្ខាសាលា និងទស្សនកិច្ចនានា ។

៦.២. ត្រៀមឯកសារពាក់ព័ន្ធនានា សម្រាប់ការទៅចូលរួមកិច្ចប្រជុំ MOU Focal Point នៅ NAY PYI TAW ប្រទេសមីយ៉ាន់ម៉ា ។

## ៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

៧.១. បានចូលរួមកិច្ចប្រជុំក្រុមការងាររៀបចំ សេចក្តីព្រាងផែនការសកម្មភាពសម្រាប់ការតភ្ជាប់សេដ្ឋកិច្ចកម្ពុជា-ឡាវ-វៀតណាមដល់ឆ្នាំ២០៣០ កាលពីថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៨ នៅទីស្តីការក្រសួងពាណិជ្ជកម្ម និងខេត្តក្រចេះ ។

៧.២. ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បាន ៖

- ចូលរួមក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ ២០១៧ និងទិសដៅការងារឆ្នាំ ២០១៨ (ថ្ងៃទី២៣-២៥ ខែមករា ឆ្នាំ២០១៨) ខេត្តបាត់ដំបង កំពង់ធំ និងខេត្តសៀមរាប
- ចូលរួមជាគណៈអធិបតីក្នុងពិធីបិទអង្គប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ២០១៧ និងទិសដៅការងារឆ្នាំ២០១៨ របស់បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស (ថ្ងៃទី២៣ ខែមករា ឆ្នាំ ២០១៨)
- ចូលរួមក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផល ការងារប្រចាំឆ្នាំ២០១៧ និងទិសដៅការងារឆ្នាំ ២០១៨ របស់ខេត្តកំពង់ឆ្នាំង កំពង់ស្ពឺ ប៉ៃលិន កែប និងខេត្តកោះកុង ពីថ្ងៃទី១៨-២៣-២៥ ខែមករា ឆ្នាំ២០១៨ ។

៧.៣. បន្តជំរុញការអនុវត្តសកម្មភាពនៃផែនការភូមិ ស គ្មានគ្រឿងញៀន ។

៧.៤. បន្តរៀបចំខ្លឹមសារសេចក្តីព្រាងទាក់ទងមាត្រាមួយចំនួន ដែលបានចែងនៅក្នុងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ពាក់ព័ន្ធនឹងការរឹបអូសទ្រព្យសម្បត្តិដែលជាផលបានមកពីបទល្មើសគ្រឿងញៀន ។

៧.៥. បន្តស្នើសុំពិនិត្យ និងសម្រេចលើសេចក្តីព្រាងព្រះរាជក្រឹត្យ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

# IV. ផែនការសកម្មភាពអនុវត្តទិសដៅត្រួតពិនិត្យគ្រឿងញៀន ខែកុម្ភៈ ឆ្នាំ២០១៨

ដើម្បីរួមចំណែកក្នុងការអនុវត្តឱ្យមានប្រសិទ្ធភាព ក្នុងការអនុវត្តផែនការសកម្មភាពយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ និងអនុវត្តផែនការជាតិស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១៨ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានដាក់ចេញនូវទិសដៅការងារសម្រាប់**ខែកុម្ភៈឆ្នាំ ២០១៨** ដូចខាងក្រោម ៖

## ១. ការអប់រំ ផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន

១.១. បន្តសហការជាមួយក្រសួងទេសចរណ៍ ដើម្បីផ្សព្វផ្សាយពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន។

១.២. បន្តសហការជាមួយក្រសួងអប់រំ យុវជន និងកីឡាលើការងារសម្របសម្រួលរៀបចំផ្សព្វផ្សាយពីគ្រោះថ្នាក់នៃការប្រើប្រាស់គ្រឿងញៀន ក្នុងគ្រឹះស្ថានសិក្សា ។

១.៣. ត្រៀមចូលរួមផ្តល់កិច្ចសម្ភាសន៍ ក្រោមប្រធានបទស្តីពី ”លទ្ធផលនៃការអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី២ របស់រាជរដ្ឋាភិបាល” នៅស្ថានីយទូរទស្សន៍ហង្សមាស ។

១.៤. បន្តសហការជាមួយស្ថានីយទូរទស្សន៍ ស៊ី.អិន.ស៊ី អញ្ជើញតំណាងក្រសួងអប់រំ យុវជន និងកីឡាចូលរួមផ្តល់កិច្ចសម្ភាសន៍ក្នុងកម្មវិធីព័ត៌មានពេលថ្ងៃត្រង់ និងតំណាងក្រសួងធម្មការ និងសាសនា ចូលរួមផ្តល់កិច្ចសម្ភាសន៍ក្នុងកម្មវិធីព័ត៌មានពេលល្ងាច ក្រោមប្រធានបទ ការអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី២ ។

១.៥. បន្តសហការជាមួយស្ថានីយទូរទស្សន៍ NICETV អញ្ជើញអភិបាលរងខេត្តរតនគិរី អភិបាលរងខេត្ត

មណ្ឌលគិរី និងអភិបាលខេត្តក្រចេះ បានចូលរួម ជាវាគ្មិនក្នុងកម្មវិធី Share (បទពិសោធន៍ខ្ញុំ) ក្រោមប្រធានបទ យុវជននិងគ្រឿងញៀន ។

១.៦. បន្តសហការជាមួយស្ថានីយទូរទស្សន៍បាយ័ន ហង្សមាស និងNICETV ដើម្បីធ្វើការផ្សព្វផ្សាយពីការងារដែលទាក់ទងនឹងបញ្ហាគ្រឿងញៀន។

១.៧. បន្តទំនាក់ទំនងជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងវិស័យឯកជន ដើម្បីបង្កើនការផ្សព្វផ្សាយអប់រំពីបញ្ហាគ្រឿងញៀនតាមវិទ្យុ ទូរទស្សន៍ និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គមផ្សេងៗ ។

១.៨. បន្តចុះអប់រំផ្សព្វផ្សាយច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន, សភាពការណ៍គ្រឿងញៀន, ចំណេះដឹងទូទៅពីគ្រឿងញៀន, ផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន នៅតាមបណ្តារោងចក្រកាត់ដេរសម្លៀកបំពាក់ និងស្បែកជើងក្នុងរាជធានីភ្នំពេញ ដោយសហការជាមួយ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

១.៩. បន្តរៀបចំកម្មវិធីប្រឡងតែងកំណាព្យ និងគូរគំនូរប្រឆាំងគ្រឿងញៀន ។

១.១០. បន្តចលនាឱ្យមានការចូលរួមពីអង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជន ក្នុងការងារអប់រំផ្សព្វផ្សាយពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន ។

១.១១. បន្តរៀបចំក្រុមការងារចងក្រងបទពិសោធន៍ និងឯកសារបង្ការការប្រើបំពានគ្រឿងញៀន នៅតាមសាលារៀន ។

១.១២. បន្តបោះពុម្ពខិត្តប័ណ្ណអប់រំពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន សម្រាប់ផ្សព្វផ្សាយអប់រំទៅលើក្រុមគោលដៅជាសិស្សានុសិស្ស ។

**២. ការកាត់បន្ថយគ្រោះថ្នាក់ ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងចាកចេញពីគ្រឿងញៀន**

២.១. បន្តចាត់បញ្ជូនមន្ត្រីសហការប្រមូលទិន្នន័យការអង្កេតរកអត្រាប្រេវ៉ាឡង់មេរោគអេដស៍ ការប្រព្រឹត្តផ្លូវភេទ និងការប៉ាន់ប្រមាណរកចំនួនអ្នកប្រើប្រាស់គ្រឿងញៀននៅប្រទេសកម្ពុជាឆ្នាំ២០១៧ ។

២.២. បន្តជំរុញសកម្មភាពផ្សព្វផ្សាយឱ្យកាន់តែសកម្ម ដើម្បីឱ្យអ្នករងគ្រោះដោយសារគ្រឿងញៀនបានដឹង និងទៅទទួលយកសេវាព្យាបាលនៅតាមមន្ទីរពេទ្យបង្អែក ឬមណ្ឌលសុខភាព ។

២.៣. បន្តការកែសម្រួលនិងពង្រឹងសមត្ថភាពគុណភាពនៃយន្តការគ្រប់គ្រងមណ្ឌលបណ្តោះអាសន្នសម្រាប់អប់រំ បន្សាប ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

២.៤. បន្តការសាងសង់មជ្ឈមណ្ឌលផ្តល់សេវាព្យាបាលដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ដល់អ្នកញៀនគ្រឿងញៀន នៅភូមិឫទ្ធី២ ឃុំ កែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ។

២.៥. បន្តជំរុញការរៀបចំសេវាព្យាបាល និងស្តារនីតិសម្បទាដល់អ្នកញៀនគ្រឿងញៀន ដែលជាទណ្ឌិតនៅ តាមមណ្ឌលអប់រំកែប្រែ និងពន្ធនាគារ ។

២.៦. ចលនា និងផ្តល់ការសម្របសម្រួលឱ្យមានការចូលរួមពីវិស័យឯកជន លើការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

**៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តន៍ច្បាប់**

៣.១. បន្តការពិនិត្យលទ្ធភាពក្នុងការបង្កើតការិយាល័យទំនាក់ទំនង (**BLO**) ថ្មី កម្ពុជា-វៀតណាម ចំនួន ២ នៅខេត្តរតនគិរី និងខេត្តកំពត ។

៣.២. ត្រៀមពិភាក្សាការងារជាមួយសមាជិកដែលពាក់ព័ន្ធអំពីការអនុវត្តគម្រោង PATROL នៅតាមព្រំដែននៃច្រកទ្វារនីមួយៗ ។

៣.៣. បន្តបណ្តុះបណ្តាលមន្ត្រីអនុវត្តន៍ច្បាប់ តាមមេរៀនក្នុងប្រព័ន្ធ e-Learning និង CBT ។

៣.៤. ជំរុញការបង្កើតក្រុមការងារត្រួតពិនិត្យគ្រឿងញៀន តាមអាកាសយានដ្ឋានអន្តរជាតិ និងកំពង់ផែសមុទ្រ ។

៣.៥. ត្រៀមរៀបចំកិច្ចពិភាក្សាជាមួយអគ្គព្រះរាជអាជ្ញានៃមហាអយ្យការសាលាឧទ្ធរណ៍ លើការងារប្រមូលទិន្នន័យបទល្មើសគ្រឿងញៀន ។

**៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ**

៤.១. បន្តការចងក្រងព័ត៌មានពាក់ព័ន្ធនឹងសារធាតុញៀនថ្មី ដែលមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ ។

៤.២. បន្តចូលរួមជាមួយក្រសួងឧស្សាហកម្មនិងសិប្បកម្ម ដើម្បីតាក់តែងបទដ្ឋានពាក់ព័ន្ធនឹងទំនិញគ្រោះថ្នាក់។

៤.៣. ត្រៀមរៀបចំកិច្ចប្រជុំក្រុមការងារអន្តរក្រសួងត្រួតពិនិត្យសារធាតុគីមីផ្សំ ។

៤.៤. ត្រៀមរៀបចំកិច្ចប្រជុំក្រុមលេខានៃក្រុមការងារអន្តរក្រសួងត្រួតពិនិត្យសារធាតុគីមីផ្សំ ។

**៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន**

៥.១. ត្រៀមទៅចូលរួមកិច្ចប្រជុំត្រីភាគី-ទ្វេភាគី កម្ពុជា-ឡាវ-វៀតណាម ដែលនឹងប្រារព្ធនៅប្រទេសឡាវ ។

៥.២. ត្រៀមរៀបចំទស្សនកិច្ចសិក្សា ស្តីពីការរឹបអូសទ្រព្យ និងចាត់ចែងទ្រព្យសម្បត្តិដែលពាក់ព័ន្ធបទល្មើសគ្រឿងញៀន ក្នុងប្រទេសថៃ នាថ្ងៃទី២៩ ខែមករា -០២ កុម្ភៈ ឆ្នាំ២០១៨ ។

៥.៣. ត្រៀមចាត់បញ្ជូនថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ១រូប ចូលរួមប្រជុំរៀបចំទទួលបដិសណ្ឋារ កិច្ចដំណើរទស្សនកិច្ចផ្លូវការ របស់គណៈប្រតិភូជាន់ខ្ពស់ក្រសួងនគរបាលនៃសាធារដ្ឋសង្គមនិយមវៀតណាម នៅរាជធានីភ្នំពេញ ។

៥.៤. បន្តអនុវត្តផែនការសកម្មភាព ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន ទ្វេភាគី កម្ពុជា-ថៃ ឆ្នាំ២០១៧-២០១៨ ។

៥.៥. បន្តអនុវត្តផែនការសកម្មភាពគម្រោងសុវត្ថិភាពទន្លេមេគង្គក្រោមសម្រាប់កម្ពុជា ថៃ ឡាវ រយៈពេល ២ឆ្នាំ (២០១៧ -២០១៨) ។

**៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា**

៦.១. ត្រៀមចាត់បញ្ជូនមន្ត្រី ចូលរួមក្នុងវគ្គបណ្តុះបណ្តាលលើកទី១៣ ស្តីពីការត្រួតពិនិត្យសារធាតុ គីមីផ្សំសម្រាប់មន្ត្រីអនុវត្តច្បាប់ក្នុងតំបន់អាស៊ាន នៅទីក្រុងបាងកក ប្រទេសថៃ ។

៦.២. ត្រៀមចាត់បញ្ជូនមន្ត្រី ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែនដោយមានការចាត់តាំង នៅសាធារណរដ្ឋកុងហ្គោ ។

៦.៣. បន្តកិច្ចសហការជាមួយមជ្ឈមណ្ឌលសម្របសម្រួលសុវត្ថិភាពទន្លេមេគង្គ Safe Mekong Coordination Center (SMCC) នៅកម្ពុជា ។

៦.៤. បន្តកិច្ចសហការសម្របសម្រួល អនុវត្តក្នុងភាពជាដៃគូលើកិច្ចសហប្រតិបត្តិការ ត្រួតពិនិត្យគ្រឿង

ៀនក្នុងក្របខ័ណ្ឌអនុតំបន់ តំបន់ អន្តរជាតិ ដូចជា សន្និសីទ វេទិកាសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន អន្តរជាតិ កិច្ចប្រជុំប្រចាំឆ្នាំ ការបណ្ដុះបណ្ដាលមន្ត្រីអនុវត្តច្បាប់ សិក្ខាសាលា និងទស្សនកិច្ចនានា ។

**៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ**

៧.១. ត្រៀមរៀបចំសន្និបាតបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១៧ និងលើកទិសដៅការងារ ឆ្នាំ២០១៨ និងកិច្ចប្រជុំបូកសរុបលទ្ធផលនៃការអនុវត្ត ផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី២ ។

៧.២. ត្រៀមការណែនាំឱ្យរាជធានី-ខេត្ត បង្កើតគណៈកម្មការសម្របសម្រួលសម្រាប់ការព្យាបាល និងស្ដារនីតិសម្បទា នៅឃុំ-សង្កាត់ ដើម្បីគាំទ្រដល់មណ្ឌលសុខភាពសម្រាប់ការព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ ។

៧.៣. ត្រៀមអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ ឆ្នាំ២០១៨ ។

៧.៤. ជំរុញការរៀបចំគោលនយោបាយ និងផែនការសកម្មភាពសម្រាប់ការងារព្យាបាល និងស្ដារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

៧.៥. បន្តរៀបចំខ្លឹមសារសេចក្ដីព្រាងទាក់ទងមាត្រាមួយចំនួន ដែលបានចែងនៅក្នុងច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀនពាក់ព័ន្ធនឹងការរឹបអូសទ្រព្យសម្បត្តិដែលជាផលបានមកពីបទល្មើសគ្រឿងញៀន ។ល។

**អគ្គលេខាធិការ**

**នាយឧត្តមសេនីយ៍ មាស-វិរិទ្ធ**

**ចម្លងជូន**

- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ឯកឧត្តម កៅ ខុនដារ៉ា អនុប្រធាន អ.ជ.ប.គ.ញ.
- ខុទ្ទកាល័យ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ.

"ដើម្បីជូនជ្រាប"

- ក្រសួង ស្ថាប័ន សមាជិក អ.ជ.ប.គ.ញ.
- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត
- នាយកដ្ឋានសរុប ទីស្ដីការគណៈរដ្ឋមន្ត្រី

"ដើម្បីមុខការ"

- ឯកសារ